# មេរៀនទី ៤៥: បងៗរបស់យ៉ូសែបលក់គាត់ឱ្យធ្វើជាទាសករ

## លោកុប្បត្តិ ៣៧:១២-៣៦

**គោលបំណង៖** ព្រះអង្គចង់ឱ្យយើងចេះស្រឡាញ់គ្នាទៅវិញទៅមក។

**ខគម្ពីរចងចាំ៖ យ៉ូហាន ១៣:៣៤** *"ខ្ញុំឲ្យសេចក្ដីបញ្ញត្ត១ថ្មីដល់អ្នករាល់គ្នា គឺឲ្យអ្នករាល់គ្នាស្រឡាញ់គ្នាទៅវិញទៅមក ត្រូវឲ្យស្រឡាញ់គ្នាដូចជាខ្ញុំបានស្រឡាញ់អ្នករាល់គ្នាដែរ។"*

**ការថ្វាយបង្គំសំរាប់គ្រូ៖ (សូមអាន ហើយអធិស្ឋានមុនពេលចាប់ផ្ដើមបង្រៀន)**

ក្នុងនាមជាគ្រីស្ទបរិស័ទដែលមានភាពចាស់ទុំក្នុងសេចក្ដីជំនឿ យើងប្រឈមមុខនឹងការតស៊ូប្រចាំថ្ងៃដើម្បីធ្វើអ្វីដែលត្រឹមត្រូវ។ សូមអានសាច់រឿងពីរូបេន និងយូដាម្ដងទៀត ហើយពិចារណាមើលពីស្ថានភាពពិបាកនៅក្នុងសាច់រឿងនោះ។ តើអ្នកធ្លាប់ប្រឈមមុខដើម្បីធ្វើអ្វីដែលត្រឹមត្រូវ ខណៈពេលដែលអ្នកដទៃធ្វើរឿងមិនត្រឹមត្រូវដែរឬទេ? សូមសរសេរកំណត់ហេតុរបស់អ្នកសប្ដាហ៍នេះ ហើយចែករំលែកជាមួយកុមារនៅក្នុងក្រុមជំនុំរបស់អ្នក។ សាច់រឿងរបស់អ្នកប្រហែលជាអាចជាការលើកទឹកចិត្តអ្នកដទៃដើម្បីធ្វើអ្វីដែលត្រឹមត្រូវ។

**ចំរៀង៖** ១. ខ្ញុំឱ្យបញ្ញត្តិថ្មី ២.ព្រះយេស៊ូវស្រឡាញ់កុមារណាស់ ៣. ក្ដីស្រឡាញ់នៃព្រះផ្អែមហើយអស្ចារ្យ

**១. អធិស្ឋាន** *(សូមនាំកុមារអធិស្ឋានបើក)*

**២. ចំរៀង** *(រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស)*

**៣. ល្បែងកំសាន្ត** « **ល្បែងផ្ទុយគ្នា** »




១. វាមានសារៈសំខាន់ណាស់សម្រាប់យើងដែលត្រូវធ្វើអ្វីតាមពាក្យដែលយើងនិយាយ បើសិនជាយើងនិយាយថាយើងនឹងមានសន្ដានចិត្តល្អ ដូច្នេះហើយយើងត្រូវតែមានចិត្តល្អ។

២. ឥឡូវនេះយើងនឹងលេងល្បែងមួយគឺសិស្សនឹងធ្វើអ្វីដែលផ្ទុយពីសំដីដែលគ្រូនិយាយ។ នៅពេលគ្រូនិយាយថា៖

- ក្រោកឈរឡើង!(សិស្សនឹងអង្គុយ)
- អង្គុយចុះ!(សិស្សនឹងក្រោកឈរ)
- ដាក់ដៃចុះប្អូនៗ(សិស្សលើកដៃឡើង)
- នៅឱ្យស្ងៀម(សិស្សងាកចុះងាកឡើង)
- ងាកទៅឆ្វេង(សិស្សងាកទៅស្ដាំ)
- កុំរាំ(សិស្សរាំ)។

៣. តើប្អូនពិបាកទេនៅពេលដែលធ្វើអ្វីផ្ទុយពីពាក្យដែលខ្ញុំនិយាយ? ព្រះចង់ឱ្យយើងធ្វើតាមទ្រង់ ព្រះអង្គមិនចង់ឲ្យយើងធ្វើខុសពីអ្វីដែលទ្រង់ប្រាប់យើងឱ្យធ្វើនោះទេ!

## ៤. ការណែនាំមេរៀន

ក្នុងសាច់រឿងកាលពីសប្តាហ៍មុន យើងបានរៀនពីក្រុមគ្រួសាររបស់យ៉ាកុប។ ក្នុងចំណោមកូនទាំង១២របស់គាត់ យ៉ូសែបជាកូនសំណព្វរបស់របស់យ៉ាកុប។ យ៉ូសែបបានប្រាប់ឪពុកពីរឿងមិនល្អរបស់បងគាត់ ហើយបន្ទាប់មក យ៉ូសែបបកស្រាយពីសុបិន្តដែលបង្ហាញថាក្រុមគ្រួសារគាត់នឹងឱនគោរពគាត់។ នៅសប្តាហ៍នេះយើងនឹងរៀនពី អ្វីដែលបានកើតឡើងនៅក្នុងគ្រួសាររបស់យ៉ាកុប នៅពេលដែលគេមិនបានស្រលាញ់គ្នាទៅវិញទៅមកដូចដែល ព្រះបានស្រលាញ់ពួកគេ។

## ៥. រឿងនៅក្នុងព្រះគម្ពីរ

ថ្ងៃមួយយ៉ាកុបបានប្រាប់យ៉ូសែបឱ្យទៅរកបងៗទាំង ១០ របស់គាត់។ ពួកគេបាននាំចៀមទៅយ៉ាងឆ្ងាយដើម្បីរក ចំណី។ យ៉ូសែបកំពុងតែដើររកបងៗរបស់គាត់ ហើយក៏បានលឺសំលេងចៀមពីចំងាយ យ៉ូសែបក៏ដើរសំដៅទៅ កន្លែងនោះ។ បងៗរបស់គាត់បានឃើញយ៉ូសែបកំពុងដើរមក ហើយដោយមានចិត្តខឹងនិងច្រណែនផងនោះ ពួក គេក៏ចាប់ផ្តើមរៀបគម្រោងធ្វើមិនល្អដាក់យ៉ូសែប។ ខ្លះនិយាយថា ពួកគេចង់ធ្វើបាបយ៉ូសែប ហើយខ្លះទៀត និយាយថា ចង់កំចាត់យ៉ូសែបចោល។

នៅពេលដែលយ៉ូសែបដើរទៅកៀកនឹងបងៗ ពួកបងក៏បានចាប់យ៉ូសែបទំលាក់ចូលអណ្តូងយ៉ាងជ្រៅ ដែលធ្វើឱ្យ គាត់មិនអាចឡើងមកវិញបាន។ រូបេនជាបងប្រុសច្បងគិតថានឹងត្រឡប់ទៅកន្លែងអណ្តូងវិញ ដើម្បីជួយស-ង្គ្រោះយ៉ូសែប តែយូដាជាអ្នកដែលមិនចង់ឱ្យយ៉ូសែបស្លាប់នៅក្នុងអណ្តូង ក៏ឱ្យយោបល់ថាលក់យ៉ូសែបឱ្យធ្វើជា ទាសកររគេទៅ។ បន្ទាប់មកពួកបងៗបានលក់យ៉ូសែបធ្វើជាទាសករឱ្យអ្នកជំនួញមួយចំនួនដែលកំពុងធ្វើដំណើរ ទៅអេស៊ីព្ទ។

ពេលដែលបងៗរបស់យ៉ូសែបត្រឡប់ទៅផ្ទះវិញ ពួកគេប្រាប់ឪពុកថាយ៉ូសែបស្លាប់ហើយ។ ឪពុករបស់យ៉ូសែប គិតថាសត្វសាហាវបានសំលាប់គាត់មែន ហើយគាត់ពិតជាកើតទុក្ខជាខ្លាំង។ បងៗរបស់យ៉ូសែបត្រូវរស់នៅ ជាមួយនឹងការកុហកនេះ។ យ៉ូសែបបានក្លាយជាទាសករនៅអេស៊ីព្ទ។

## ៦. សំនួរពិភាក្សា

១. តើបងៗរបស់យ៉ូសែបបានបង្ហាញក្តីស្រលាញ់ចំពោះប្អូនពួកគេដែលឬទេ? *អត់ទេ*

២. តើសកម្មភាពអ្វីខ្លះដែលបងៗរបស់យ៉ូសែបបានធ្វើដាក់គាត់?

*បងៗចាប់ប្អូនទំលាក់ទៅក្នុងអណ្តូង និងលក់គាត់ឱ្យទៅធ្វើជាទាសករ*

៣. តើប្អូននឹងធ្វើបែបណានៅពេលដែលប្អូនខឹងនឹងបងប្អូនបង្កើតរបស់ប្អូន? *សូមឱ្យកុមារជាអ្នកឆ្លើយ*

## ៧. ល្បែងកំសាន្ត «ខ្លែងឆាបកូនមាន់»



១. បែងចែកកុមារជា ២ក្រុម ឬច្រើនជាងនេះ

២. ក្នុងក្រុមនីមួយៗកុមារត្រូវតោងចង្កេះគ្នា។ អ្នកដែលនៅឈរមុខគេគឺត្រូវតាមចាប់យកអ្នកក្រោយគេនៃក្រុមផ្សេងទៀត ហើយក៏ត្រូវព្យាយាមការពារកូនក្រុមខ្លួនឯងផងដែរ (អ្នកដែលនៅកន្ទុយក្រោយគេ)

៣. គោលបំណងនៃល្បែងនេះគឺបង្ហាញពីការព្យាយាមការពារគ្នាទៅវិញទៅមក។ ក្រុមដែលតោងគ្នាមិនជាប់ (នឹងចាញ់ហ្គេមនេះដោយស្វ័យប្រវត្តិ) ហើយក្រុមដែលមានសមាជិករបស់ខ្លួនត្រូវគេចាប់បានក៏ចាញ់ហ្គេមនេះដែរ។

## ៨. ខគម្ពីរចងចាំ យ៉ូហាន ១៣:៣៤

**កាយវិការចងចាំខគម្ពីរ៖**

- លើកដៃទាំងពីរទៅលើរួចប្រើចង្អុលដៃទាំងសងខាងចង្អុលទៅលើនិយាយថា (ខ្ញុំឱ្យ)
- ទម្លាក់ដៃទាំងពីរទៅខាងមុខ លាបាតដៃ (សេចក្ដីបញ្ញត្តិ)
- លើកដៃម្ខាងធ្វើជាសញ្ញាលេខ 1 អាចប្រើចង្អុលដៃ (១ ថ្មី)
- ដាក់ដៃទាំង ២ ទៅខាងមុខ យកបាតដៃខ្វែងគ្នា (ដល់អ្នករាល់គ្នា គឺឱ្យអ្នករាល់គ្នា)
- យកដៃទាំង២ ធ្វើរូបបេះដូង (ស្រឡាញ់គ្នា)
- លាបាតដៃទាំងពីរទៅមុខ (ទៅវិញ)
- ទាញដៃទាំងពីរត្រលប់មករកខ្លួនយើងវិញ (ទៅមក)
- យកដៃទាំង២ ធ្វើរូបបេះដូង(ត្រូវឱ្យស្រឡាញ់គ្នាដូចជាខ្ញុំបានស្រឡាញ់អ្នករាល់គ្នាដែរ)។

## ៩. ហត្ថកម្ម «ខ្ញុំស្រលាញ់អ្នក »




១. បត់ក្រដាសពាក់កណ្ដាលហើយដាក់ដៃ អ្នកដានលើក្រដាសនោះ



២. បត់ក្រដាសតាមដានដៃរបស់អ្នក ប៉ុន្តែកុំកាត់ផ្ដាច់គែមនៃមេដៃ និងម្រាមដៃចង្អុល



៣. សូមលាដៃទាំងសងខាងហើយសរសេរថា “ខ្ញុំស្រលាញ់អ្នក” ហើយ យកក្រដាសជូនដល់ឪពុកម្ដាយប្អូន(ឬបងប្អូនស្រីប្រុសរបស់ប្អូន)

**១០. ចំរៀង** *(រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស)*

**១១. អធិស្ឋាន** *(សូមនាំកុមារអធិស្ឋានបិទ)*